# មានផ្តល់ជូនការសិក្សាស្រាវជ្រាវការដ្ឋានសម្រាប់ក្រុមហ៊ុន Glacier Northwest Inc.



*ទិដ្ឋភាពនៃការដ្ឋាននេះ មើលពីផ្លូវ W Marginal Way SW ។*

## មតិយោបល់ដែលបានទទួលយកពីៈ

ថ្ងៃទី 1 ខែមិថុនា (ម៉ោង 12:00 នាទីព្រឹក) ដល់ ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2026 (ម៉ោង 11:59 នាទីសៀល)

## ដាក់បញ្ជូនមតិយោបល់៖

**អនឡាញ៖**

https://go.ecology.wa.gov/commentglaciernw

**តាមប្រៃសណីយ៍៖**

Cliff Nale, Site Manager
PO Box 330316
Shoreline, WA 98133-9716
cliff.nale@ecy.wa.gov
425-725-0438

## ការពិនិត្យមើលឯកសារ៖

https://go.ecology.wa.gov/glaciernw

បណ្ណាល័យសាធារណៈSeattle (Seattle Public Library)

សាខា South Park (South Park Branch)

8604 8th Ave S., Seattle

## ព័ត៌មានអំពីការដ្ឋាន៖

5900 W Marginal Way SW Seattle, WA

ខេលសម្គាល់ទីតាំងក្បួន៖ 23881883

ខេលសម្គាល់ការសម្អតក្បួន៖ 599

## ទំនាក់ទំនងផ្សព្វផ្សាយសាធារណៈ៖

Meredith Waldref
អ្នករៀបចំផែនការផ្សព្វផ្សាយ
meredith.waldref@ecy.wa.gov
425-229-3683

## ផ្តល់មតិយោបល់លើការសិក្សាបរិស្ថានសម្រាប់ការដ្ឋាននៃទន្លេ Lower Duwamish Waterway

យើងខ្ញុំសូមអញ្ជើញអ្នកចូលរួមផ្តល់មតិយោបល់លើលទ្ធផលនៃការសិក្សាបរិស្ថាន ដែលរៀបរាប់អំពីការបំពុលដែលត្រូវបានរកឃើញនៅទីតាំងក្រុមហ៊ុន Glacier Northwest, Inc.។ ការដ្ឋាននេះស្ថិតនៅតាមបណ្តោយមាត់ទន្លេនៃ Lower Duwamish Waterway (LDW) តាមបណ្តោយផ្លូវ W Marginal Way SW និងនៅខាងជើងកំពង់ផែនៃទីក្រុង Seattle ស្ថានីយ 115។

ឯកសារខាងក្រោមនេះត្រូវបានដាក់ជូនសម្រាប់ការពិនិត្យមើល និងផ្តល់មតិយោបល់៖

**របាយការណ៍ស៊ើបអង្កេតដើម្បីស្វែងរកដំណោះស្រាយ៖** ការសិក្សាបរិស្ថានមួយ ដែលស្វែងរកការពិតថា តើមានការបំពុលអ្វីខ្លះ និងតើវាបានរីករាលដាលដល់ទីណាខ្លះ។ វាជួយឆ្លើយតបទៅនឹងសំណួរនានាដូចជា "តើមានសារធាតុបំពុលអ្វីខ្លះនៅទីនេះ ?", "តើពួកវាស្ថិតនៅចំទីតាំងណាពិតប្រាកដ ?", និង "តើវាមានបរិមាណច្រើនប៉ុនណា ?"

## ស្វែងយល់បន្ថែមនៅក្នុងម៉ោងធ្វើការក្នុងសហគមន៍របស់យើង!

សូមអញ្ជើញមកចូលរួមក្នុងអំឡុងពេលព្រឹត្តិការណ៍សហគមន៍ដែលមានរយៈពេលពីរម៉ោងនេះ ដើម្បីពិភាក្សាអំពីទីតាំងសម្អាតនេះ។ មានសេវាបកប្រែភាសាតាមទូរស័ព្ទ។ សូមស្វាគមន៍សម្រាប់មនុស្សគ្រប់វ័យ!

**ថ្ងៃពុធ ទី 3 ខែមិថុនា ឆ្នាំ 2026**
**(ម៉ោង 4:00 ល្ងាច ដល់ 6:00 ល្ងាច)**

ទីលានលេងកម្សាន្ត South Park (South Park Playground)
738 S Sullivan St., Seattle, WA 98108

## សេវាកម្មបកប្រែភាសា

Español (p. 3), 中文 (見第 3頁), Tiếng Việt (Trang 3), ភាសាខ្មែរ (ទំព័រ 3)

## ប្រវត្តិនៃការដ្ឋាន

ក្រុមហ៊ុន Glacier Northwest, Inc. គឺជាម្ចាស់បច្ចុប្បន្ននៃអចលនទ្រព្យនេះ ដែលកាលពីមុនត្រូវបានដំណើរការដោយក្រុមហ៊ុន Reichhold, Inc. ដែលជាអ្នកផលិត និងចែកចាយផលិតផលគីមី។

- **ឆ្នាំ 1913 ដល់ 1922៖** ផ្នែកដីគោកនៃអចលនទ្រព្យនេះ ត្រូវបានចាក់បំពេញដោយសម្ភារៈដែលបានមកពីការបូមកាយស្តារ និងការតម្រង់ផ្លូវទឹកជាលើកដំបូងនៃផ្លូវទឹក LDW។
- **ឆ្នាំ 1936 ដល់ 1939៖** ក្រុមហ៊ុន រក្សាការពារឈើ Mineralized-Cell (Mineralized-Cell Wood Preserving Company) បានជួលផ្នែកមួយនៃអចលនទ្រព្យនេះពី King County ហើយបានកែច្នៃឈើដុំមូលដោយប្រើប្រាស់សូលុយស្យុងដែលមានផ្ទុកសារធាតុទង់ដែង, អាសេនិក, និងស័ង្កសី នៅផ្នែកខាងត្បូងនៃអចលនទ្រព្យនេះ។
- **ឆ្នាំ 1940 ដល់ 1944៖** ធ្យូងសកម្ម (សម្រាប់ប្រើប្រាស់ក្នុងរបាំងការពារហ្គាស) ត្រូវបានផលិត និងធ្វើតេស្តដោយក្រុមហ៊ុន Carlisle Lumber Company ហើយបន្ទាប់មកដោយសាជីវកម្ម Crown Zellerbach Corporation ក្រោមកិច្ចសន្យា និងការត្រួតពិនិត្យដោយ US Army។ កងទ័ពបានទិញផ្នែកដីគោកនៃអចលនទ្រព្យនេះនៅក្នុងឆ្នាំ 1943។
- **ឆ្នាំ 1946 ដល់ 1961៖** ក្រុមហ៊ុន Reichhold, Inc. បានជួលដីនេះពីកងទ័ព ហើយបានប្រើប្រាស់អចលនទ្រព្យនេះសម្រាប់ការផលិតសារធាតុគីមី រួមមាន ជ័រ ការ ហ្វរម៉ាល់ដេអ៊ីត (formaldehyde) ប៉ង់តាក្លរ៉ូហ្វេណុល (pentachlorophenol) និងសូដ្យូម ប៉ង់តាក្លរ៉ូហ្វេណាត (sodium pentachlorophenate) នៅតាមដំណាក់កាលផ្សេងៗគ្នាក្នុងអំឡុងពេលនៃប្រតិបត្តិការរបស់ខ្លួន។
- **ឆ្នាំ 1964៖** កំពង់ផែទីក្រុង Seattle (Port of Seattle) បានទិញអចលនទ្រព្យនេះ ហើយបានជួលវាបន្តទៅឱ្យក្រុមហ៊ុន Kaiser Cement Corp ដែលជាភាគីមានកាតព្វកិច្ចត្រូវអភិវឌ្ឍអចលនទ្រព្យនេះឡើងវិញ សម្រាប់ការរក្សាទុក និងការចែកចាយស៊ីម៉ងត៍។ ក្រុមហ៊ុន Kaiser បានអភិវឌ្ឍអចលនទ្រព្យនេះឡើងវិញ ហើយស្ថានីយរក្សាទុក និងចែកចាយស៊ីម៉ងត៍ត្រូវបានបើកដំណើរការនៅចន្លោះឆ្នាំ 1968 ឬ 1969។
- **ឆ្នាំ 1968/69 ដល់បច្ចុប្បន្ន៖** អចលនទ្រព្យនេះត្រូវបានប្រើប្រាស់ជាចម្បងជាស្ថានីយរក្សាទុក និងចែកចាយស៊ីម៉ងត៍ ក្រោមការគ្រប់គ្រងរបស់ម្ចាស់ និងអ្នកដំណើរការអចលនទ្រព្យផ្សេងៗគ្នា ហើយផ្នែកខាងត្បូងនៃអចលនទ្រព្យនេះ ត្រូវបានជួលជាបណ្តើរៗសម្រាប់ទុកដាក់ឧបករណ៍ទៅឱ្យអង្គភាពផ្សេងទៀត។ អចលនទ្រព្យនេះត្រូវបានគ្រប់គ្រងជាកម្មសិទ្ធិដោយក្រុមហ៊ុន Glacier Northwest, Inc. ចាប់តាំងពីឆ្នាំ 1991 មក។




ទីតាំងក្រុមហ៊ុន Glacier Northwest ស្ថិតនៅចន្លោះការដ្ឋានសម្អាតពីរផ្សេងទៀត គឺទីតាំងរោងចក្រជួសជុលនិងផលិតកប៉ាល់ Duwamish និងស្ថានីយភាគខាងជើង 115។ ការសម្អាតនៅគ្រប់ការដ្ឋានទាំងអស់នេះ ត្រូវបានត្រួតពិនិត្យដោយ Ecology។

## ការស៊ើបអង្កេតដើម្បីស្វែងរកដំណោះស្រាយ៖ ការសិក្សាអំពីការបំពុលនៅនឹងកន្លែង

នៅក្នុងឆ្នាំ 2009 យើងខ្ញុំបានចុះកិច្ចព្រមព្រៀងតាមដីកាសម្រេច ជាមួយក្រុមហ៊ុន Glacier Northwest, Inc. និងក្រុមហ៊ុន Reichhold, Inc. (ដែលជាបុគ្គលអាចទទួលខុសត្រូវចំពោះការខូចខាត ឬហៅកាត់ថា PLPs) ដើម្បីស៊ើបអង្កេតការបំពុលនៅទីតាំងនេះ។ ការស៊ើបអង្កេតនេះត្រូវបានគេហៅថា ជាការស៊ើបអង្កេតដើម្បីស្វែងរកដំណោះស្រាយ។ ការស៊ើបអង្កេតនេះបានរកឃើញនូវសារធាតុបំពុលចម្បងៗដែលគួរឱ្យព្រួយបារម្ភដូចខាងក្រោម ដែលអាចនឹងតម្រូវឱ្យមានការសម្អាត៖

- **ដី៖** សារធាតុលោហៈ (អាសេនិក, ទង់ដែង, ស័ង្កសី, ទ្រីប៊ុយទីលទីន), សារធាតុសមាសធាតុសរីរាង្គពាក់កណ្តាលងាយហួត (semi-volatile organic compounds, SVOCs) - ប៉ង់តាក្លរ៉ូហ្វេណុល, 2,4,6-ទ្រីក្លរ៉ូហ្វេណុល, 2,4-ឌីក្លរ៉ូហ្វេណុល, ហិចសាក្លរ៉ូប៊ីង់សែន, ប៊ីស (2-អេទីលហិចស៊ីល) ហ្វតាលីត, ហ្វេណុល), សារធាតុ (polychlorinated biphenyls, PCBs), សារធាតុឌីអុកស៊ីន/ហ្វូរ៉ង់, សារធាតុអ៊ីដ្រូកាបូនប្រេងកាតសរុប (total petroleum hydrocarbons, TPH) ជាប្រភេទប្រេងម៉ាស៊ូត និង/ឬ ប្រេងម៉ាស៊ីន និងសារធាតុអ៊ីដ្រូកាបូនក្រអូបពហុវង់ដែលបង្កជំងឺមហារីក (carcinogenic polycyclic aromatic hydrocarbons, cPAHs)
- **ទឹកក្រោមដី៖** សារធាតុលោហៈ, សារធាតុ SVOCs, សារធាតុ PCBs, សារធាតុឌីអុកស៊ីន/ហ្វូរ៉ង់ (dioxins/furans), សារធាតុ TPH, សារធាតុ cPAHs
- **ដីល្បាប់បាតទន្លេ៖** សារធាតុលោហៈ, សារធាតុ SVOCs, សារធាតុ PCBs, សារធាតុឌីអុកស៊ីន/ហ្វូរ៉ង់ (dioxins/furans), សារធាតុ TPH, សារធាតុ cPAHs

## តើអ្វីនឹងកើតឡើងបន្ទាប់ ?

ជំហានបន្ទាប់នៅក្នុងដំណើរការសម្អាតសម្រាប់ការដ្ឋាននេះ គឺការបង្កើតការសិក្សាអំពីលទ្ធភាពជាក់ស្តែង ដែលវាយតម្លៃលើជម្រើសសម្អាតជាច្រើន និងផ្តល់អនុសាសន៍អំពីវិធីសាស្ត្រដែលល្អបំផុតដើម្បីដោះស្រាយការបំពុលនេះ។ ឯកសារនេះនឹងត្រូវដាក់ជូនជាសាធារណៈសម្រាប់រយៈពេលផ្តល់មតិយោបល់ផងដែរ។




ការដ្ឋានរបស់ក្រុមហ៊ុន Glacier Northwest, Inc. គឺស្ថិតនៅក្នុងផ្នែកខាងក្រោម។

## ហេតុអ្វីបានជាការដ្ឋាននេះមានសារៈសំខាន់

ទីតាំងនេះស្ថិតនៅតាមបណ្តោយតំបន់ Superfund (LDW) នៃទន្លេ [Lower Duwamish Waterway][1] ដែលមានបណ្តោយ 5 ម៉ាយល៍ពីទន្លេ Duwamish River។ ទីភ្នាក់ងារការពារបរិស្ថាន (Environmental Protection Agency, EPA) បានដាក់បញ្ចូល [តំបន់ Superfund LDW][2] ទៅក្នុងបញ្ជីអាទិភាពជាតិ Superfund នៅក្នុងឆ្នាំ 2001។ Ecology កំពុងធ្វើការដើម្បីបញ្ឈប់ ឬកាត់បន្ថយប្រភពបំពុលទៅកាន់តំបន់ Superfund LDW ជាការខិតខំប្រឹងប្រែងដែលស្គាល់ថាជា "[ការគ្រប់គ្រងប្រភព][3]" ដើម្បីឱ្យ EPA អាចបន្តការសម្អាតដីល្បាប់ក្នុងទន្លេបាន។

## ដំណើរការសម្អាតរបស់យើង

ច្បាប់ស្តីពីការគ្រប់គ្រងសារជាតិពុលគំរូ (Model Toxics Control Act, [MTCA][4])គឺជាច្បាប់ស្តីពីការសម្អាតបរិស្ថានរបស់រដ្ឋ Washington។ ច្បាប់នេះផ្តល់លក្ខខណ្ឌតម្រូវសម្រាប់ការសម្អាតទីតាំងដែលមានការបំពុល និងកំណត់ស្តង់ដា ដែលការពារសុខភាពមនុស្ស និងបរិស្ថាន។ Ecology ទទួលខុសត្រូវក្នុងការគ្រប់គ្រង MTCA រួមទាំងការត្រួតពិនិត្យការសម្អាត។ [ដំណើរការសម្អាតរបស់ MTCA][5] ត្រូវបញ្ចប់ជាជំហានៗ ( សូមមើលក្រាហ្វិកខាងក្រោម ) តាមបន្ទាត់ពេលវេលាដែលប្រែប្រួលមួយ។




### សេវាកម្មបកប្រែភាសា

**Español**: Para ver una copia de esta hoja informativa en español, go.ecology.wa.gov/glaciernw, the Seattle Public Library South Park Branch, llama al (360) 407-6097, o manda un correo electrónico a preguntas@ecy.wa.gov.
**中文**: 要查看 中文 情况说明书, 请访问西雅图公共图书馆南公园分馆 go.ecology.wa.gov/glaciernw, the Seattle Public Library South Park Branch 致電 (425)229-3683, 或電子郵件 meredith.waldref@ecy.wa.gov。
**Tiếng Việt:** Để xem bản sao của Tờ Thông Tin này bằng tiếng Việt, hãy truy cập trang mạng: go.ecology.wa.gov/glaciernw, the Seattle Public Library South Park Branch, hoặc gọi (425) 229-3683, hoặc gửi email đến meredith.waldref@ecy.wa.gov.
**ភាសាខ្មែរ** ដើម្បីមើលឯកសារថតចម្លងតារាងព័ត៌មាននេះជាភាសា ភាសាខ្មែរ សូមចូលមើលវិបសាយ go.ecology.wa.gov/glaciernw, សាខា Seattle Public Library South Park Branch, សូមហៅទូរស័ព្ទលេខ (425) 229-3683, ឬអ៊ីមែល meredith.waldref@ecy.wa.gov.

---

[1] https://ecology.wa.gov/LDW
[2] https://www.epa.gov/superfund/lower-duwamish
[3] https://ecology.wa.gov/LDW-source-control
[4] https://ecology.wa.gov/mtca
[5] https://ecology.wa.gov/MTCA-process

Toxics Cleanup Program
PO Box 330316
Shoreline, WA 98133-9716

# ផ្តល់មតិយោបល់លើការសិក្សាបរិស្ថានសម្រាប់ការដ្ឋានសម្អាត Lower Duwamish

Español (p. 3) | 中文 (見第 3頁) | Tiếng Việt (Trang 3)
ភាសាខ្មែរ (ទំព័រ 3)

**អំឡុងពេលផ្តល់មតិយោបល់សាធារណៈ:**
**ថ្ងៃទី 1 ខែមិថុនា (ម៉ោង 12:00 ព្រឹក) – ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2026 (ម៉ោង 11:59 យប់)**
ការសិក្សាអំពីការបំពុលសម្រាប់ការដ្ឋានក្រុមហ៊ុន Glacier Northwest, Inc.គឺឯកសារអាចរកបានសម្រាប់ការត្រួតពិនិត្យ និងមតិយោបល់។ ការដ្ឋានសម្អាតនេះគឺមានទីតាំងស្ថិតនៅតាមបណ្តោយទន្លេ Lower Duwamish Waterway។

សូមអញ្ជើញមកចូលរួមជាមួយយើងខ្ញុំ ដោយផ្ទាល់ នៅក្នុងម៉ោងធ្វើការ នៅថ្ងៃទី 3 ខែមិថុនា ដើម្បី ស្វែងយល់បន្ថែម និងសាកសួររកព័ត៌មាន!
លម្អិតបន្ថែមមាននៅលើទំព័រទី 1។




ផែនទីពីលើអាកាសនៃការដ្ឋានក្រុមហ៊ុន Glacier Northwest។

**លទ្ធភាពចូលប្រើច្បាប់ស្តីពីជនពិការអាមេរិក (Americans with Disabilities Act, ADA)**
ដើម្បីស្នើសុំការសម្រួលសម្រួលពី ADA សូមទាក់ទងមកពួកយើង តាមទូរសព្ទលេខ 425-533-5537 ឬអ៊ីមែល LDW@ecy.wa.gov ឬចូលមើលគេហទំព័រ ecology.wa.gov/Accessibility។ សម្រាប់សេវាបញ្ជូនបន្ត ឬ TTY សូមទូរសព្ទទៅលេខ 711 ឬ 877-833-6341។